# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងអគ្គនាយកដ្ឋានពន្ធដារ ព្រះរាជាណាចក្រកម្ពុជាជាមួយអគ្គនាយកដ្ឋានចំណូល នៃព្រះរាជាណាចក្រថៃ

### ទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ថ្ងៃទី១៣ - ១៤ ខែកក្កដា ឆ្នាំ២០១៧



© *រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

ក្នុងដំណើរទស្សនកិច្ចផ្លូវការរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូ នៃអគ្គនាយកដ្ឋានពន្ធដារកម្ពុជារួមមាន ឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ លោក អេង រតនា ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ មកកាន់ទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ដើម្បីជួបប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយអគ្គនាយកដ្ឋាន ចំណូលនៃព្រះរាជាណាចក្រថៃដឹកនាំដោយ ឯកឧត្តម Prasong Poontaneat អគ្គនាយក នៃអគ្គនាយកដ្ឋានចំណូល នៃព្រះរាជាណាចក្រថៃ ដើម្បីពិភាក្សាលើការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី លើការងារពន្ធដារពាក់ព័ន្ធនឹងការចែករំលែកបទពិសោធន៍ ការបង្វិលសង អាករលើតម្លៃបន្ថែមសម្រាប់ទេសចរបរទេស, ការធ្វើទំនើបកម្មពន្ធដារប្រព័ន្ធព័ត៌មានវិទ្យា, យន្តការពិនិត្យផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម, និងការពិភាក្សាកិច្ចព្រមព្រៀងនៃការចៀសវាងការយកពន្ធត្រួតគ្នា។

ក្នុងគោលដៅទាក់ទាញទេសចរបរទេស ធ្វើដំណើរចូល

មកនិងទិញទំនិញនានាក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមអនុសាសន៍និងការចង្អុលបង្ហាញរបស់ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល បានចាត់ក្រុមការងារបច្ចេកទេសនៃអគ្គនាយកដ្ឋានពន្ធដារ ធ្វើការសិក្សាស្រាវជ្រាវនិងរៀបចំយន្តការ សម្រាប់ការបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់ទេសចរបរទេស (VAT Refund for Tourists)។ ក្នុងឱកាសនេះផងដែរ តាមរយៈកិច្ចប្រជុំនេះ គណៈប្រតិភូបានពិភាក្សាស្វែងយល់ និងសិក្សារៀនសូត្រពីអគ្គនាយកដ្ឋានចំណូល នៃព្រះរាជាណាចក្រថៃ អំពីយន្តការគ្រប់គ្រង បទពិសោធន៍នៃការអនុវត្ត និងបច្ចេកវិទ្យាព័ត៌មាន គាំទ្រដល់ការបង្វិលសងអាករលើតម្លៃបន្ថែម សម្រាប់ទេសចរបរទេស (VAT Refund for Tourists)។

បន្ថែមពីលើនេះ ក្នុងរយៈពេលពីរថ្ងៃនៃកិច្ចប្រជុំពិភាក្សា គណៈប្រតិភូបានធ្វើការពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកព័ត៌មានគ្នា អំពីយន្តការពិនិត្យផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម (VAT Cross Check) ដែលជាការងារអាទិភាពគាំទ្រដល់ការធ្វើសវនកម្ម ការកាត់កងឥណទានអាករ និងការបង្វិលសងអាករលើតម្លៃបន្ថែមជូនសហគ្រាសនានា។ នេះគឺជាការងារអាទិភាព ក្នុងចំណោមការងារអាទិភាពនានាស្របតាមការអនុវត្តនូវយុទ្ធសាស្ត្រ កៀរគរចំណូល RMS ២០១៤-២០១៨។

ក្នុងឱកាសនៃកិច្ចប្រជុំនេះ ថ្នាក់ដឹកនាំកំពូល នៃអគ្គនាយកដ្ឋានពន្ធដារទាំងទ្វេភាគី បានឯកភាពគ្នាជាគោលការណ៍អនុញ្ញាតឱ្យក្រុមការងារបច្ចេកទេស DTA នៃប្រទេសទាំងពីរជំរុញដំណើរការកិច្ចចរចារ កិច្ចព្រមព្រៀងនៃការចៀសវាងការយកពន្ធត្រួតគ្នា (DTA) នៅដើមខែសីហា ឆ្នាំ២០១៧ ដែលនឹងអាចឈានទៅបញ្ចប់ និងការចុះកិច្ចព្រមព្រៀងឱ្យបានឆាប់ផងដែរ ដែលនេះនឹងជាអាចជាដំណឹងដ៏ល្អមួយ សម្រាប់អ្នកវិនិយោគិន និងពាណិជ្ជករនៃប្រទេសទាំងពីរ នឹងទទួលបានប្រយោជន៍ផ្នែកពន្ធដារ តាមរយៈកិច្ចព្រមព្រៀងនេះ៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ